ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អគ្គិសនីកម្ពុជា
គណៈកម្មាធិការលទ្ធកម្ម
លេខ : ៣៨៤៩ PC.អក

# សេចក្តីជូនដំណឹង
## ស្តីពីការពន្យារពេលបើកឯកសារដេញថ្លៃជាលក្ខណៈអន្តរជាតិ និងដេញថ្លៃប្រកួតប្រជែងជាសាធារណៈផ្សេងៗ ចំនួន ១៣ គម្រោង

**យោង** ៖ ការចាំបាច់របស់អគ្គិសនីកម្ពុជា ។

អគ្គិសនីកម្ពុជាសូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជា ដែលបានទិញឯកសារដេញថ្លៃប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ និងដេញថ្លៃប្រកួតប្រជែងជាសាធារណៈ ឲ្យបានជ្រាបថា ៖ អគ្គិសនីកម្ពុជាស្នើសុំពន្យារពេលការបើកឯកសារដេញថ្លៃគ្រប់គម្រោងទាំងអស់ ដែលបានផ្សព្វផ្សាយជូនដំណឹងជាសាធារណៈរួចមកហើយ ដើម្បីធ្វើការសិក្សា ពិនិត្យមើលលើលក្ខណៈបច្ចេកទេសឡើងវិញក្នុងឯកសារដេញថ្លៃ រួមមានគម្រោងដូចខាងក្រោម ៖

I . ដេញថ្លៃប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ ៖

1).ការផ្គត់ផ្គង់ MV SWITCH-DISCONNECTOR ចំនួន 16 មុខ (Category-2) សម្រាប់គម្រោងការងារបន្តចរន្ត ជួសជុល ថែទាំ និងកែលម្អបណ្តាញ ជូន អគ្គិសនីខេត្តចំនួន ១៥ (ផែនការឆ្នាំ២០២០) (ត្រូវបើកឯកសារ ដេញថ្លៃ នៅថ្ងៃទី 12-តុលា-2021) ។

II . ដេញថ្លៃប្រកួតប្រជែងជាសាធារណៈ ៖

1).ការងារក្រាលការ៉ូឡា, ចាក់បេតុង, ធ្វើរោងដាក់រថយន្តស្ទូច, រថយន្តកន្ត្រក និងសាងសង់ប្រឡាយទឹក ជូន អគ្គិសនីបន្ទាយមានជ័យ (ត្រូវបើកឯកសារដេញថ្លៃ នៅថ្ងៃទី 12-តុលា-2021) ។

2).ការផ្គត់ផ្គង់ Yearly Maintenance & Training សម្រាប់ប្រព័ន្ធពន្លត់អគ្គីភ័យ FM 200 (កញ្ចប់ លេខ ១១-២) ជូន អង្គភាពអនុស្ថានីយ នៃ នាយកដ្ឋានបញ្ជូនអគ្គិសនី (ត្រូវបើកឯកសារដេញថ្លៃ (លើកទី២) នៅ ថ្ងៃទី 14-តុលា-2021) ។

3).សេវាកម្មដឹកជញ្ជូន តម្លើង ប្រមូលប្រាក់បង់សងរំលស់ និងថែទាំប្រព័ន្ធ SHS-500Wp និងមានថ្មផ្ទាំងដាំបាយអគ្គិសនីប្រភេទ Panasonic ចំណុះ ០៤ លីត្រ ចំនួន 2,612 ប្រព័ន្ធ ក្រោមកម្មវិធីប្រព័ន្ធ SHS ឆ្នាំ ២០២១ (ត្រូវបើកឯកសារដេញថ្លៃ (លើកទី២) នៅថ្ងៃទី 19-តុលា-2021) ។

4).ការផ្គត់ផ្គង់ Refill Gas សម្រាប់ប្រព័ន្ធពន្លត់អគ្គីភ័យ FM 200 (កញ្ចប់លេខ១១-១) ជូន អង្គភាពអនុស្ថានីយ នៃ នាយកដ្ឋានបញ្ជូនអគ្គិសនី (ត្រូវបើកឯកសារដេញថ្លៃ (លើកទី២) នៅថ្ងៃទី 19-តុលា-2021) ។

5).ការផ្គត់ផ្គង់ Steel Pole សម្រាប់បម្រុង ចំនួន ០៤ មុខ (កញ្ចប់លេខ២១) ជូន អង្គភាពខ្សែបញ្ជូន នៃ នាយកដ្ឋានបញ្ជូនអគ្គិសនី (ផែនការឆ្នាំ២០២០) (ត្រូវបើកឯកសារដេញថ្លៃ នៅថ្ងៃទី 20-តុលា-2021) ។

6).ការផ្គត់ផ្គង់និងដំឡើងឧបករណ៍ ផ្តាច់-ភ្ជាប់ពីចំងាយ ចំនួន ០៣ មុខ ជូន អគ្គិសនីបន្ទាយមានជ័យ និងអគ្គិសនីកំពង់ស្ពឺ (ផែនការឆ្នាំ២០២១) (ត្រូវបើកឯកសារដេញថ្លៃ នៅថ្ងៃទី 20-តុលា-2021) ។

7).ការផ្គត់ផ្គង់ CB Operation Box ចំនួន ០១ មុខ (កញ្ចប់លេខ១៩) សម្រាប់ប្រើប្រាស់នៅអនុស្ថានីយអគ្គិសនីអូរសោម ជូន អង្គភាពអនុស្ថានីយ នៃ នាយកដ្ឋានបញ្ជូនអគ្គិសនី (ផែនការឆ្នាំ ២០២១) (ត្រូវបើកឯកសារដេញថ្លៃ នៅថ្ងៃទី 26-តុលា-2021) ។

8).ការផ្គត់ផ្គង់និងដំឡើង Barracuda Email Security Gateway Application 400 ចំនួន ០១ គ្រឿង ជូន នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន (ត្រូវបើកឯកសារដេញថ្លៃ នៅថ្ងៃទី 26-តុលា-2021) ។

9).ការជួសជុល និង Calibration ម៉ាស៊ីនតេស្តបរិក្ខាអគ្គិសនី Omicron ចំនួន ១៣ មុខ (កញ្ចប់លេខ១០) ជូន អង្គភាពខ្សែបញ្ជូន នៃ នាយកដ្ឋានបញ្ជូនអគ្គិសនី (ផែនការឆ្នាំ២០២១) (ត្រូវបើកឯកសារដេញថ្លៃ នៅ ថ្ងៃទី 28-តុលា-2021) ។

10).ការផ្គត់ផ្គង់ ឧបករណ៍បច្ចេកទេស ចំនួន ០២ មុខ (កញ្ចប់លេខ០៨) សម្រាប់ប្រើប្រាស់នៅតាមបណ្តាអនុស្ថានីយអគ្គិសនីនិងខ្សែបញ្ជូន ជូន អង្គភាពអនុស្ថានីយ នៃ នាយកដ្ឋានបញ្ជូនអគ្គិសនី (ផែនការឆ្នាំ ២០២១) (ត្រូវបើកឯកសារដេញថ្លៃ នៅថ្ងៃទី 28-តុលា-2021) ។

11).ការផ្គត់ផ្គង់ ឧបករណ៍បច្ចេកទេស ចំនួន 09 មុខ ជូន អគ្គិសនីខេត្តចំនួន ១២ (ផែនការឆ្នាំ២០២០) (ត្រូវបើកឯកសារដេញថ្លៃ នៅថ្ងៃទី 02-វិច្ឆិកា-2021) ។

12).ការងារសាងសង់របងទប់ដី ប្រវែង 281m និងចាក់ដីបន្ថែម 6,297.60m³ នៅសាខាជាំក្រវៀន ជូន អគ្គិសនីត្បូងឃ្មុំ (ត្រូវបើកឯកសារដេញថ្លៃ នៅថ្ងៃទី 02-វិច្ឆិកា-2021) ។

អគ្គិសនីកម្ពុជា នឹងរៀបចំជូនដំណឹងសារជាថ្មី នាពេលក្រោយ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមលោក-លោកស្រី ជ្រាបជាព័ត៌មាន តាមការគួរ ។

ថ្ងៃចន្ទ ៥កើត ខែ កក្តិក ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ ១០ ឆ្នាំ ២០២១

ជ.ប្រធានគណៈកម្មាធិការលទ្ធកម្ម

ហាច់_ទូច

**ចម្លងជូន:**
-អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
-អង្គភាពប្រឆាំងអំពើពុករលួយ
ដើម្បីជូន "ជ្រាប"
-នាយកដ្ឋានរដ្ឋបាល
-នាយកដ្ឋានអាជីវកម្មចែកចាយ
-នាយកដ្ឋានបញ្ជូនអគ្គិសនី
-នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន
-អគ្គិសនីបន្ទាយមានជ័យ-អគ្គិសនីត្បូងឃ្មុំ-អគ្គិសនីកំពង់ស្ពឺ
ជូន "ជាព័ត៌មាន"
-ឯកសារ-កាលប្បវត្តិ